# បទបង្ហាញ
# ស្ដីពី
# ការទទួលស្គាល់ជាសន្តតិជន និងការបែងចែកមត៌ក

*សន្និបាតវិស័យយុត្តិធម៌ ឆ្នាំ២០២៥,ថ្ងៃទី១២ ដល់ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៥*

*រៀបចំដោយ៖  ឯកឧត្តម* ***ញាន វណ្ណៈ****, ឯកឧត្តម* ***ឡូច សំណាង*** *និងលោក* ***ឡោ គ្រឹម***

# មាតិកា


- ភាពចាំបាច់នៃប្រធានបទ
- ចំណោទបញ្ហាគតិយុត្ត
- បទប្បញ្ញត្តិច្បាប់ជាមូលដ្ឋាន
- ការសន្និដ្ឋាន
- សំណើសុំការសម្រេចពីអង្គសន្និបាត

# ១-ភាពចាំបាច់នៃប្រធានបទ

១-បណ្ដឹងចូលមក **គ២** ឃើញថា ពាក្យសុំអន្តរាគមន៍ចំពោះចំណាត់ការពាក់ព័ន្ធនឹងសំណុំរឿងសន្តិកម្មមានចំនួនប្រមាណ **១៣%** នៃពាក្យសុំអន្តរាគមន៍សរុប នៃសំណុំរឿងរដ្ឋប្បវេណី។

២-ផ្អែកតាមលទ្ធផលនៃការពិនិត្យលើពាក្យសុំអន្តរាគមន៍ទាំងនេះ, ក្រុមការងារ **គ២** រកឃើញថា ការអនុវត្តមួយចំនួន មិនបានត្រឹមត្រូវតាមច្បាប់ ពាក់ព័ន្ធនឹងពាក្យសុំទាមទារឱ្យទទួលស្គាល់ជាសន្តតិជន និងការទាមទារឱ្យបែងចែកមត៌ក។

៣-តុលាការក្លាយជាមធ្យោបាយរបស់ភាគីក្នុងការបំពានសិទ្ធិរបស់ភាគីផ្សេងទៀត។

៤-ការប្រើប្រាស់សិទ្ធិអំណាចស្រាវជ្រាវដោយឆន្ទានុសិទ្ធិ និងការប្រើប្រាស់សិទ្ធិបំភ្លឺរបស់ចៅក្រមទទួលបន្ទុកសំណុំរឿងសន្តិកម្ម នៅមានកម្រិតនៅឡើយ និងមិនទាន់បានឆ្លើយតបនឹងគោលបំណងនៃច្បាប់ជាធរមាន។

៥-មានសេចក្តីសម្រេចរបស់តុលាការ ដែលសម្រេចកែប្រែមតកសាសន៍ដោយលិខិតយថាភូតធ្វើឡើងដោយសារការី ដែលធ្វើឱ្យប៉ះពាល់ដល់ទំនុកចិត្តលើលិខិតសារការី និងទំនុកចិត្តលើវិជ្ជាជីវៈសារការី។

៦-សេចក្តីសម្រេចរបស់តុលាការមួយចំនួន មិនអាចយកទៅអនុវត្តបាន និងពុំបានបញ្ចប់វិវាទរបស់គូភាគីនៃរឿងក្តីទាំងស្រុងនៅឡើយ។

# សំណុំរឿងដែលមិនមានភាគីម្ខាងទៀត



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង

លេខ៖ ០៩០ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣

ដីកាសម្រេចលេខ៖ ២៧១ ដកសរ/ខ ២៣

ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣

ដីកាសម្រេច

យើង [redacted] ចៅក្រមទទួលបន្ទុករឿងក្ដី នៃសាលាដំបូងខេត្តកណ្ដាល ។

ដោយមានលោក [redacted] ជាក្រឡាបញ្ជី ។

- បានឃើញ៖ ក្រមរដ្ឋប្បវេណី ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧។
- បានឃើញ៖ ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ប្រកាសឲ្យប្រើដោយព្រះរាជក្រម នស/រកម/០៧១០/០១៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០។
- បានឃើញ៖ សំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹងលេខ៖ ០៩០ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ ២០២៣ របស់សាលាដំបូងខេត្តកណ្ដាល ។

ក- អត្តសញ្ញាណភាគី ៖

+ អ្នកដាក់ពាក្យសុំ ឈ្មោះ ពៅ សាវ៉ាង ភេទស្រី កើតថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៦៨ ជនជាតិខ្មែរ និងឈ្មោះ សុទ្ធា តាវ៉ា ភេទប្រុស កើតថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៩៣ មានទីលំនៅបច្ចុប្បន្នភូមិកណ្ដាលកោះ ឃុំកោះឧកញ៉ាតី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ។

អ្នកតំណាងដោយអាណត្តិ លោក ហួត សុខជា អត្តលេខ២០៤០ មេធាវី នៃក្រុមមេធាវី អេច ប៊ី អ និង សហការី មានអាសយដ្ឋានតាំងនៅអគារផ្សារស៊ីធីម៉ល ជាន់ទី២ មហាវិថីមុនីរ៉េត (២១៧) សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

+ ភាគីម្ខាងទៀត ៖ គ្មាន ។

ខ. ខ្លឹមសារនៃសេចក្ដីសម្រេចដែលទាមទារឲ្យតុលាការចេញ៖

អ្នកដាក់ពាក្យសុំ៖ ឈ្មោះ **ពៅ សាវ៉ាង** និងឈ្មោះ **សុទ្ធា តាវ៉ា**

ភាគីម្ខាងទៀត៖ **គ្មាន**

# ការសម្រេចទទួលស្គាល់ជាសន្តតិជន និងទាមទារបែងចែកមត៌ក នៅក្នុងសំណុំរឿងតែមួយ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍បាត់ដំបង

សតារដ្ឋប្បវេណី
សំណុំរឿងលេខ: ០៨៣
ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤
**ដីកាសម្រេចលេខ: ៧៦ "ខ"**
ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤

**ដីកាសម្រេច**
**ក្នុងនាមប្រជារាស្ត្រខ្មែរ**
**សាលាឧទ្ធរណ៍បាត់ដំបង**
បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់
នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤

**សេចក្តីសម្រេចបញ្ចប់**

១-ទទួលពាក្យបណ្តឹងជំទាស់លេខ ១៨ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៤ របស់អ្នកដាក់ពាក្យសុំឈ្មោះ ហែម សុថៅ ប្តឹងជំទាស់នឹងដីកាសម្រេចលេខ ២១៣ ពស.រវ/ឈ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តសៀមរាប ទុកជាត្រឹមត្រូវតាមច្បាប់។

២-លុបចោលដីកាសម្រេចលេខ ២១៣ ពស.រវ/ឈ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តសៀមរាប។

៣-ទទួលស្គាល់ចំណុចទី១ និងទី២ នៅក្នុងពាក្យសុំដីកាសម្រេចបែងចែកមត៌ក ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ របស់អ្នកដាក់ពាក្យសុំឈ្មោះ ហែម សុថៅ។

10

៤-ច្រានចោលចំណុចទី៣ នៅក្នុងពាក្យសុំដីកាសម្រេចបែងចែកមត៌ក ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ របស់អ្នកដាក់ពាក្យសុំឈ្មោះ ហែម សុថៅ។

៥-ទទួលស្គាល់អ្នកដាក់ពាក្យសុំឈ្មោះ ហែម សុថៅ ជាសន្តតិជននៃមតកជនឈ្មោះ ចាប សុវារី។

៦-ប្រគល់អចលនវត្ថុ (ដី) ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ 17100401-1868 ក្បាលដីលេខ 1868 ទំហំ 4792ម$^2$ ស្ថិតនៅភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប និងអចលនវត្ថុ (ដី) ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ 17100401-1320 ក្បាលដីលេខ 1320 ទំហំ 2940ម$^2$ ស្ថិតនៅភូមិវត្តបូព៌ សង្កាត់ សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ឱ្យទៅអ្នកដាក់ពាក្យសុំឈ្មោះ ហែម សុថៅ។

៧-ប្រាក់ប្រដាប់ក្តីនៅសាលាឧទ្ធរណ៍ជាបន្ទុករបស់អ្នកដាក់ពាក្យសុំ។

*ដីកាសម្រេចនេះ ប្រកាសជាសាធារណៈ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤។*

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |

៥-ទទួលស្គាល់អ្នកដាក់ពាក្យសុំឈ្មោះ **ហែម សុថៅ** ជាសន្តតិជននៃមតកជនឈ្មោះ **ចាប សុវារី**។

៦-ប្រគល់អចលនវត្ថុ(ដី) ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ 17100401-1868 និង លេខ 17100401-1320 ឱ្យទៅអ្នកដាក់ពាក្យសុំឈ្មោះ **ហែម សុថៅ**។

# ទ្រព្យជាមូលដ្ឋាននៃសន្តតិកម្មតែមួយ ប៉ុន្តែមានសេចក្តីសម្រេចបែងចែកពីរផ្ទុយផ្សេងគ្នា


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍បាត់ដំបង
សំណុំរឿងរដ្ឋប្បវេណី
សំណុំរឿងលេខ: ០៨៣
ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤
ដីកាសម្រេចលេខ: ៧៦ "ខ"
ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤

ដីកាសម្រេច
ក្នុងនាមប្រជារាស្ត្រខ្មែរ
សាលាឧទ្ធរណ៍បាត់ដំបង
បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់
នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤
សមាសភាពអង្គជំនុំជម្រះ

សេចក្តីសម្រេចបញ្ចប់

១-ទទួលពាក្យបណ្តឹងជំទាស់លេខ ១៨ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៤ របស់អ្នកដាក់ពាក្យសុំឈ្មោះ ហែម សុចៅ ប្តឹងជំទាស់នឹងដីកាសម្រេចលេខ ២១៣ ពស.រវ/ឈ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តសៀមរាប ទុកជាត្រឹមត្រូវតាមច្បាប់។

២-លុបចោលដីកាសម្រេចលេខ ២១៣ ពស.រវ/ឈ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តសៀមរាប។

៣-ទទួលស្គាល់ចំណុចទី១ និងទី២ នៅក្នុងពាក្យសុំដីកាសម្រេចបែងចែកមត៌ក ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ របស់អ្នកដាក់ពាក្យសុំឈ្មោះ ហែម សុចៅ។

10

៤-ច្រានចោលចំណុចទី៣ នៅក្នុងពាក្យសុំដីកាសម្រេចបែងចែកមត៌ក ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ របស់អ្នកដាក់ពាក្យសុំឈ្មោះ ហែម សុចៅ។

៥-ទទួលស្គាល់អ្នកដាក់ពាក្យសុំឈ្មោះ ហែម សុចៅ ជាសន្តតិជននៃមតកជនឈ្មោះ ចាប សុភារី។

៦-ប្រគល់អចលនវត្ថុ (ដី) ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ 17100401-1868 ក្បាលដីលេខ 1868 ទំហំ 4792ម² ស្ថិតនៅភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប និងអចលនវត្ថុ (ដី) ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ 17100401-1320 ក្បាលដីលេខ 1320 ទំហំ 2940ម² ស្ថិតនៅភូមិវត្តបូព៌ សង្កាត់ សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ឱ្យទៅអ្នកដាក់ពាក្យសុំឈ្មោះ ហែម សុចៅ។

៧-ប្រាក់ប្រដាប់ក្តីនៅសាលាឧទ្ធរណ៍ជាបន្ទុករបស់អ្នកដាក់ពាក្យសុំ។

*ដីកាសម្រេចនេះ ប្រកាសជាសាធារណៈ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤។*

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
| --- | --- | --- |
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប
លេខ: ៨៤៩៥ ពស.រទ/ជ
ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៤

ដីកាសម្រេច

យើង [redacted] ចៅក្រមសាលាដំបូងខេត្តសៀមរាប

-បានឃើញច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១០/០១៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០។

-បានឃើញមាត្រា១១៤៧ វាក្យខណ្ឌទី១ មាត្រា ១១៦០ មាត្រា ១២៧០ និងមាត្រាពាក់ព័ន្ធនៃក្រមរដ្ឋប្បវេណី។

-បានឃើញសំណុំរឿងរដ្ឋប្បវេណីដែលមិនមែនបណ្តឹងលេខ ៥៩៤៣ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ ២០២៤ ដែលមាន៖

ក-អ្នកដាក់ពាក្យសុំ

-ឈ្មោះ ចាប សុភ័ក្ត្រ ភេទប្រុស អាយុ ៥២ឆ្នាំ ជនជាតិខ្មែរ មុខរបរ អគ្គីសនីកម្ពុជា មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ។

-អ្នកតំណាងដោយអាណត្តិឲ្យអ្នកដាក់ពាក្យសុំលោកមេធាវី ថោង ចាន់រិទ្ធី អត្តលេខ ៧២៩ មានការិយាល័យផ្ទះលេខ ១៣៣ អ៊ី ១ ផ្លូវលេខ ១១៣ សង្កាត់បឹងប្រលឹត ខណ្ឌ 7 មករា រាជធានីភ្នំពេញ ។

ខ-សហតាគីម្នាក់ទៀតនៃអ្នកដាក់ពាក្យសុំ

១-ឈ្មោះ ចាប ណេ ភេទប្រុស កើតឆ្នាំ១៩៦៥ ជនជាតិខ្មែរ មានអាស័យដ្ឋានបច្ចុប្បន្ននៅភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ។

២-ឈ្មោះ ចាប បូរិន ភេទស្រី កើតឆ្នាំ១៩៦៩ ជនជាតិខ្មែរ មានអាស័យដ្ឋានបច្ចុប្បន្ននៅភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ។

សេចក្តីសម្រេចបញ្ចប់

១-បែងចែកមត៌កជាអចលនវត្ថុ (ដី) ចំនួន ០២ កន្លែង ដែលមាន៖

ក-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលវត្ថុលេខ 17100401-1868 មានទំហំ 4792 ម² ដែលមានទីតាំងនៅភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ចេញដោយប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តសៀមរាប និង

ខ-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលវត្ថុលេខ 17100401-1320 ទំហំ 2940 ម² ដែលមានទីតាំងនៅភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ចេញដោយប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តសៀមរាប របស់មតកជនឈ្មោះ ចាប សុភារី ។

ទៅអោយសន្តតិជន ជាចំណែកស្មើៗគ្នា ចំពោះសន្តតិជនដែលមានដូចខាងក្រោម៖

ក-ឈ្មោះ ចាប សុភ័ក្ត្រ ភេទប្រុស អាយុ ៥២ឆ្នាំ ជនជាតិខ្មែរ មុខរបរ អគ្គីសនីកម្ពុជា មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ។

ខ-ឈ្មោះ ចាប ណេ ភេទប្រុស កើតឆ្នាំ១៩៦៥ ជនជាតិខ្មែរ មានអាស័យដ្ឋានបច្ចុប្បន្ននៅភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ។

គ-ឈ្មោះ ចាប បូរិន ភេទស្រី កើតឆ្នាំ១៩៦៩ ជនជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្ននៅភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ។

**អ្នកដាក់ពាក្យសុំ ដាច់ដោយឡែកពីគ្នា**

**សំណុំរឿងទី១៖** សម្រេចប្រគល់ដី លេខ **17100401-1868** និង លេខ **17100401-1320** ទៅឱ្យឈ្មោះ **ហែម សុចៅ ។**

**សំណុំរឿងទី២៖** សម្រេចបែងចែកដី លេខ **17100401-1868** និង លេខ **17100401-1320** ទៅឱ្យសហសន្តតិជនឈ្មោះ **ចាប សុភ័ក្រ** , ឈ្មោះ **ចាប ណេ** , ឈ្មោះ **ចាប បូរិន។**

**ដីកាសម្រេចខាងលើ ស្ថាពរទាំងពីរ**

# សំណុំរឿងទទួលស្គាល់ជាសន្តតិជន និងបែងចែកមត៌ក ប៉ុន្តែភាគីមានវិវាទលើទ្រព្យជាមូលដ្ឋាននៃសន្តតិកម្ម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

លេខ ០៣៥ ន.ម.ប.ណ/២០

**ដីកាសម្រេច**

យើង [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល

**ហេតុដូច្នេះសម្រេច**

១. ទទួលស្គាល់សន្តតិជនចំនួន ៦នាក់ ជាសន្តតិជនរបស់មតកជនឈ្មោះ **ឡាច សុទ្ធ** និង ឈ្មោះ **លាង ត្រិត** ដែលមានឈ្មោះដូចខាងក្រោម ៖

១.១. ឈ្មោះ ឡាច តិចលី ភេទស្រី កើតថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ១៩៥៣

១.២. ឈ្មោះ ឡាច ឈុន ភេទប្រុស កើតថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៥៦

១.៣. ឈ្មោះ សៀ គីមសាំង ភេទស្រី កើតថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៨០ (កូនស្រីបង្កើតឈ្មោះ ឡាច សៀ) ជាសន្តតិជនជំនួសឈ្មោះ ឡាច សៀ

១.៤. ឈ្មោះ ឡាច សាំងវ៉ុង (ឡាច វ៉ុង) ភេទស្រី កើតថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៦៩

១.៥. ឈ្មោះ ឡាច ស៊ាង (សុត ស្រ៊ាង) ភេទប្រុស

១.៦. ឈ្មោះ ឡាច សុខ ភេទប្រុស ។

២. បែងចែកដី (អចលនវត្ថុ) ដែលមានក្បាលដីលេខ ៣១ ទំហំ ១៦៥ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិស្វាយជ្រុំ ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្តាល ដែលមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៩០ ជាប្រាំមួយចំណែក ដោយឈ្មោះ **ឡាច ស៊ាង** (សុត ស្រ៊ាង) ទទួលបានចំណែក ២៦,៦៦ % (ភាគរយ) នៃអចលនវត្ថុ ឈ្មោះ **ឡាច សាំងវ៉ុង** ទទួលបានចំណែក ២៦,៦៦ % (ភាគរយ) នៃអចលនវត្ថុ ឈ្មោះ **ឡាច សុខ** ទទួលបានចំណែក ២៦,៦៦ % (ភាគរយ) នៃអចលនវត្ថុ ឈ្មោះ **ឡាច តិចលី** ទទួលបានចំណែក ៦,៦៦ % (ភាគរយ) នៃអចលនវត្ថុ ឈ្មោះ **ឡាច ឈុន** ទទួលបានចំណែក ៦,៦៦ % (ភាគរយ) នៃអចលនវត្ថុ និង ឈ្មោះ **សៀ គីមសាំង** ទទួលបានចំណែក ៦,៦៦ % (ភាគរយ) នៃអចលនវត្ថុ ។

---

ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

**ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ ដីធ្លី**

ខ្ញុំបាទ នាងខ្ញុំឈ្មោះ ________ ភេទ ________ អាយុ ________ សញ្ជាតិ ________
ប្រពន្ធ ប្តី ឈ្មោះ ________ សមាជិកក្នុងគ្រួសារសរុប 6 នាក់ ទីលំនៅ។ ភូមិ ________
ឃុំ ________ ស្រុក ________ ខេត្ត ________ ។

**សូមគោរពជូន**

សមមិត្តប្រធានគណៈកម្មាធិការប្រជាជនស្រុក ________

*តាមរយៈ:* – សមមិត្តប្រធានភូមិ ________

– សមមិត្តប្រធានគណៈកម្មាធិការប្រជាជនឃុំ ________

– សមមិត្តប្រធានការិយាល័យកសិកម្មស្រុក ________

*កម្មវត្ថុ* : សំណើសុំកាន់កាប់ប្រើប្រាស់ ដីធ្លី

ដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ នាងខ្ញុំ បានកាន់កាប់ប្រើប្រាស់ដី(១) ________ នៅភូមិ ________ ឃុំ ________ ស្រុក ________ ខេត្ត ________ ដែលមានទំហំ 1650 m² ចាប់ពីឆ្នាំ ១៩79 មកទល់បច្ចុប្បន្ន ។
ដីនេះ មានព្រំប្រទល់

# សំណុំរឿងសន្តតិកម្ម ដែលតុលាការសម្រេចលុបចោលមតកសាសន៍ ដោយលិខិតយថាភូត ធ្វើឡើងដោយសារការី និងបែងចែកមត៌កតាមច្បាប់ឡើងវិញ



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ ១៨២ "ជ".ដ.ម

ដីកាសម្រេច
រឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ: មាត្រា ៣ តារាងឧបសម្ព័ន្ធ ផ្នែកទី ៤ ចំណុចទី ១៥ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ។

-បានឃើញ: សំណុំរឿងរដ្ឋប្បវេណីលេខ ៥៣២ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ។

អ្នកដាក់ពាក្យសុំ

១-ឈ្មោះ តា សុផល្លា ភេទស្រី កើតថ្ងៃ២៣ ខែតុលា ឆ្នាំ១៩៥៩ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ 72 Guan Soon Avenue Singapore

១០-តាមពាក្យសុំលុបចោល ពាក្យសុំដីកាសម្រេចបែងចែកមត៌ករបស់មតកជនឈ្មោះ តា វ:សត្ថា ស្នើសុំឲ្យតុលាការចេញដីកាសម្រេចលើកចោលពាក្យសុំដីកាសម្រេចបែងចែកមត៌ករបស់មតកជនឈ្មោះ តា វ:សត្ថា ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ របស់លោកមេធាវី ផេង ស៊ីដេត ដោយមូលហេតុខុសគិតច្បាប់ របស់លោកមេធាវី ហេង ឆាយ និងលោកមេធាវី អ៊ុក ឡុងឌី ជាមេធាវីតំណាងដោយអាណត្តិរបស់ឈ្មោះ តា រដ្ឋមត: និងឈ្មោះ តា សុវណ្ណី ដោយបានលើកឡើងសុំឲ្យតុលាការធ្វើការបែងចែកតាមមតកសាសន៍ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១២ វេលាម៉ោង ១២ និង ៤០ នាទីថ្ងៃត្រង់ ធ្វើនៅសិង្ហបុរី របស់លោក តា វ:សត្ថា ឃើញថា: មតកសាសន៍ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១២ របស់លោក តា វ:សត្ថា នៅក្នុងចំណុចទី ៤.៥.២ ត្រូវអនុវត្តការបែងចែកដូចខាងក្រោម:

| | | | |
|---|---|---|---|
| ១០.១-ឈ្មោះ តា សុផល្លា | (កូនស្រី) | ៖ | 0% |
| ១០.២-ឈ្មោះ តា សុវណ្ណា | (កូនស្រី) | ៖ | 0% |
| ១០.៣-ឈ្មោះ តា សុវណ្ណី | (កូនស្រី) | ៖ | ៣៣.៣% |
| ១០.៤-ឈ្មោះ តា រដ្ឋាភិរម្យ | (កូនប្រុស) | ៖ | 0% |
| ១០.៥-ឈ្មោះ តា រដ្ឋាមត: | (កូនប្រុស) | ៖ | ៦៦.៦% |
| ១០.៦-ឈ្មោះ តា សុវណ្ណមុនីកា | (កូនស្រី) | ៖ | 0% |

-ដូច្នេះការបែងចែកនៅក្នុង មតកសាសន៍ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១២ របស់លោក តា វ:សត្ថា ឃើញថាពុំមានសមភាពក្នុងចំណោម សន្តតិជនទាំងអស់នោះឡើយ ។



១២-តាមមាត្រា ៣ ឧបសម្ព័ន្ធផ្នែកទី ២ ចំណុចទី ៥ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង តុលាការមានសត្ថកិច្ចចេញដីកាសម្រេចតាមពាក្យសុំរបស់អ្នកដាក់ពាក្យសុំ ។

សម្រេច

I-បែងចែកទ្រព្យសម្បត្តិ ដែលមានដូចខាងក្រោម:

I.១-វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ 12080102-1440 ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០១២ មានទីតាំងនៅភូមិពោងពាង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

I.២-វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ 12080102-1441 ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០១២ មានទីតាំងនៅភូមិពោងពាង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

I.៣-វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ 12080102-1437 ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០១២ មានទីតាំងនៅភូមិពោងពាង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

I.៤-វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ 12080102-1233 ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០១២ មានទីតាំងនៅភូមិពោងពាង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

I.៥-វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ 12080102-1438 ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០១២ មានទីតាំងនៅភូមិពោងពាង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

I.៦-វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ 12080102-1439 ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០១២ មានទីតាំងនៅភូមិពោងពាង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

I.៧-ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ កស 005439 ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០០៦ មានទីតាំងនៅភូមិច្រេស ឃុំជើងរាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ។

I.៨-ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ កស 005441 ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០០៦ មានទីតាំងនៅភូមិច្រេស ឃុំជើងរាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ។

I.៩-ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ កស 005442 ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០០៦ មានទីតាំងនៅភូមិច្រេស ឃុំជើងរាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ។

I.១០-ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ កស 005443 ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០០៦ មានទីតាំងនៅភូមិច្រេស ឃុំជើងរាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ។

I.១១-ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ កស 005444 ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០០៦ មានទីតាំងនៅភូមិច្រេស ឃុំជើងរាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ។

I.១២-ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ កស 005445 ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០០៦ មានទីតាំងនៅភូមិច្រេស ឃុំជើងរាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ។

11

**មតកសាសន៍ដោយលិខិតយថាភូត ដែលធ្វើឡើងដោយសារការី ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១២**

**-សំអាងហេតុតុលាការ៖** ការបែងចែកនៅក្នុងមតកសាសន៍ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១២ របស់លោក **តា វ:សត្ថា** ឃើញថា ពុំមានសមភាពក្នុងចំណោម សន្តតិជនទាំងអស់ឡើយ។ តុលាការគប្បីធ្វើតាមមាត្រា ១១៥៦ កថាខណ្ឌទី២។

**-សេចក្តីសម្រេច៖** បែងចែកទ្រព្យសម្បត្តិ ជា៦ចំណែក ទៅឱ្យសហសន្តតិជន...។

# សំណុំរឿងបែងចែកមត៌ក ប៉ុន្តែភាគីមានវិវាទលើទ្រព្យជាមូលដ្ឋាននៃសន្តតិកម្ម



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ

ដីកាសម្រេច

សំណុំរឿងដីកាសម្រេច

លេខ ១៧៦(ឋ)/០៨-១២-២០២១

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នា ថ្ងៃទី...

ខែមេសា ឆ្នាំពីរពាន់ម្ភៃបី ដោយមាន៖

**សេចក្តីសម្រេចបញ្ចប់**

១-ទទួលបណ្តឹងជំទាស់លេខ ១៩១ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១ របស់ឈ្មោះ ហ្វ ពេជ្ររតនា មេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ ស៊ិន ប៉ោងនជា ទុកជាត្រឹមត្រូវតាមច្បាប់ ។

២.លុប ដីកាសម្រេចលេខ ៧៧០ "ង" ដម ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ហើយសម្រេចជាថ្មីដូចខាងក្រោម៖

-បែងចែកដីដែលមានក្នុងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ភព ០៦៦៩៧ ចុះ... ខែតុលា ឆ្នាំ២០០៤ បំបែកទៅជាដីដែលមានក្នុងវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២១១០២០៥-០៣៤០,លេខ ១២១១០២០៥-០៣៤១,លេខ ១២១១០២០៥-០៣៤២,លេខ ១២១១០២០៥-០៣៤៣,លេខ

១៧

១២១១០២០៥-០៣៤៤ និងលេខ ១២១១០២០៥-០៣៤៥ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ ដែលមានទីតាំងស្ថិតនៅភូមិគៀនឃ្លាំង សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ជា ៥ចំណែកស្មើៗគ្នា ឱ្យទៅភាគីអ្នកដាក់ពាក្យសុំមានឈ្មោះ ស៊ិន ប៉ោងនជា និងសហភាគីម្ខាងទៀតឈ្មោះ ស៊ិន ខូច និងប្តីឈ្មោះខុន ឡុន ,ឈ្មោះ ស៊ិន ប៉ោសៀន និងប្រពន្ធឈ្មោះ ខូច ឈីវហ្វយ ,ឈ្មោះ ស៊ិន ប៉ោស្រ៊ិន និងប្រពន្ធឈ្មោះ វ៉ែ ប៊ុនអេង ឈ្មោះ ស៊ិន សុខណាប និងប្តីឈ្មោះ ធីន អេងឡុង ។

២.ការទាមទារផ្សេងពីនេះត្រូវច្រានចោល ។

៣. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីអ្នកដាក់ពាក្យសុំ ។

-ដីកាសម្រេចនេះ ប្រកាសជាសាធារណៈ នៅថ្ងៃ ពុធ ៥ កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០២៣ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |



ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ ដីធ្លី

ខ្ញុំបាទ នាងខ្ញុំឈ្មោះ ... ភេទ ... អាយុ ... សញ្ជាតិ ...

ប្រពន្ធ ប្តី ឈ្មោះ ... សមាជិកក្នុងគ្រួសារសរុប ០៣ នាក់ ទីលំនៅ ភូមិ ...

ឃុំ ... ស្រុក ... ខេត្ត ...

សូមគោរពជូន

សមមិត្តប្រធានគណៈកម្មាធិការប្រជាជនស្រុក ...

តាមរយៈ - សមមិត្តប្រធានភូមិ ...

- សមមិត្តប្រធានគណៈកម្មាធិការប្រជាជនឃុំ ...

- សមមិត្តប្រធានការិយាល័យកសិកម្មស្រុក ...

កម្មវត្ថុ : សំណើសុំកាន់កាប់ប្រើប្រាស់ ដីធ្លី

ដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ នាងខ្ញុំ បានកាន់កាប់ប្រើប្រាស់ដី(១) ... នៅភូមិ ... ឃុំ ... ស្រុក ...

ខេត្ត ... ដែលមានទំហំ ... ចាប់ពីឆ្នាំ ១៩... មកទល់បច្ចុប្បន្ន ។

ដីនេះ មានព្រំប្រទល់ :

២-លុបចោលដីកាសម្រេច...របស់សាលាដំបូងរាជធានីភ្នំពេញ ហើយសម្រេចជាថ្មីដូចខាងក្រោម៖

-បែងចែកដីដែលមានក្នុងប័ណ្ណលេខ ភព ០៦៦៩៧ បំបែកទៅជាដីមានក្នុងប័ណ្ណលេខ 12110205-0340 , 0341 , 0342 , 0343 , 0344 , 0345 ជា ៥ចំណែកស្មើៗគ្នា ឱ្យទៅឈ្មោះ... , ឈ្មោះ ... , ឈ្មោះ ... , ឈ្មោះ ..., ឈ្មោះ...។

# ២-ចំណោទបញ្ហាគតិយុត្ត

១-តើតាមច្បាប់ បណ្ដឹងទាមទារឱ្យទទួលស្គាល់ជាសន្តតិជន និងទាមទារបែងចែកមត៌ក អាចបញ្ចូលក្នុងបណ្ដឹងតែមួយ និងប្រើប្រាស់នីតិវិធីតែមួយដូចការអនុវត្តបច្ចុប្បន្នបានដែរ ឬទេ ?

២-តើបណ្ដឹងទាមទារឱ្យទទួលស្គាល់ជាសន្តតិជន និងទាមទារបែងចែកមត៌ក ត្រូវប្រើប្រាស់នីតិវិធីណា ? ប្រើច្បាប់នីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ឬច្បាប់នីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ឬនីតិវិធីទូទៅតាមក្រមនីតិវិធីរដ្ឋប្បវេណី ?

៣-តើដីកាសម្រេចនៅក្នុងនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង អាចសម្រេចអំពីវិវាទសិទ្ធិលើកម្មសិទ្ធិនៃទ្រព្យជាមូលដ្ឋាននៃសន្តតិកម្មបាន ឬទេ (ក្នុងករណីដែលមានសន្តតិជនណាម្នាក់អះអាងថា ទ្រព្យនោះមិនមែនជាទ្រព្យសន្តតិកម្ម ជាកម្មសិទ្ធិរបស់ខ្លួន) ?

៤-តើការសម្រេចបែងចែកមត៌ក ដែលមិនបានធ្វើការពិចារណាលើទ្រព្យសកម្ម និង បំណុលរបស់មតកជនជាមុន ជាការសម្រេចត្រឹមត្រូវដែរ ឬទេ ? តើការសម្រេចបែបនេះ តុលាការអាចវិនិច្ឆ័យអំពីភាគបម្រុងបានយ៉ាងដូចម្ដេច ?

៥-តើតុលាការមានកាតព្វកិច្ចសម្រេចអំពីភាគបម្រុងដែរ ឬទេ ?

៦-តើទ្រព្យដែលជាកម្មវត្ថុនៃសន្តតិកម្ម ជាទ្រព្យជាប់ធានាកាតព្វកិច្ច អាចជាកម្មវត្ថុនៃ ការបែងចែកបានដែរ ឬទេ ?

៧-តើតុលាការអាចសម្រេចបែងចែកទ្រព្យដែលជាកម្មវត្ថុនៃសន្តតិកម្ម ជាទ្រព្យធានា កាតព្វកិច្ចបានដែរ ឬទេ ? តើការបែងចែកនេះ ប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បំណុល ដូចមាន កំណត់ក្នុងមាត្រា ១២៦៩ នៃក្រមរដ្ឋប្បវេណី ដែរ ឬទេ ?

# ៣-បទប្បញ្ញត្តិច្បាប់ជាមូលដ្ឋានទាក់ទងនឹងប្រធានបទ

| | | | |
|---|---|---|---|
| ច្បាប់ ស្តីពី នីតិវិធីបណ្តឹង ទាក់ទងនឹងឋានៈ បុគ្គល | ច្បាប់ ស្តីពី នីតិវិធីនៃរឿងក្តី រដ្ឋប្បវេណីដែល មិនមែនជាបណ្តឹង | ក្រម នីតិវិធីរដ្ឋប្បវេណី | ក្រមរដ្ឋប្បវេណី |

# ក-វិសាលភាពនៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

**មាត្រា ៣ (វិសាលភាពនៃច្បាប់នេះ)** បានចែងថា "ច្បាប់នេះមានអានុភាពអនុវត្តលើបណ្តឹងទាក់ទងនឹងឋានៈបុគ្គល៖

-បណ្តឹងទាមទារឱ្យបញ្ជាក់អំពីមោឃភាពនៃអាពាហ៍ពិពាហ៍

-បណ្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍

-បណ្តឹងទាមទារលែងលះ

-បណ្តឹងបដិសេធបិតុភាព

-បណ្តឹងទាមទារឱ្យទទួលស្គាល់ តាមបញ្ញត្តិមាត្រា ១០០១

-បណ្ដឹងដែលមានគោលបំណងបញ្ជាក់អំពីនត្តិភាពនៃបុត្តភាព  តាមបញ្ញត្តិមាត្រា ១០០២

-បណ្ដឹងដែលមានគោលបំណងបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព

-បណ្ដឹងទាមទារកាត់កាល់ តាមបញ្ញត្តិមាត្រា ១០១៦

-បណ្ដឹងទាមទារកាត់កាល់ តាមបញ្ញត្តិមាត្រា ១០៣១

**-បណ្ដឹងផ្សេងទៀតដែលមានគោលបំណងបង្កើត បញ្ជាក់អត្ថិភាព ឬនត្តិភាពនៃទំនាក់ទំនងឋានៈបុគ្គល។**

# ខ-វិសាលភាពនៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណី ដែលមិនមែនជាបណ្ដឹង

- **មាត្រា ៣ កថា.១ (វិសាលភាពនៃច្បាប់នេះ)៖** ច្បាប់នេះអនុវត្តចំពោះពាក្យសុំដែលមានកំណត់នៅក្នុងផ្នែកនីមួយៗនៃតារាងឧបសម្ព័ន្ធនៃច្បាប់។ ផ្អែកតាមតារាងឧបសម្ព័ន្ធនៃច្បាប់នេះ ការបែងចែកមត៌កដែលធ្វើឡើងតាមនីតិវិធីនៃច្បាប់នេះ គឺការបែងចែកមត៌កដែលធ្វើឡើងតាមកថាខណ្ឌទី១ នៃមាត្រា១២៧០ នៃក្រមរដ្ឋប្បវេណី។ ការទទួលស្គាល់សន្តតិជនមិនមានក្នុងតារាងឧបសម្ព័ន្ធនេះទេ។
- **កថាខណ្ឌទី១ នៃមាត្រា១២៧០ នៃក្រមរដ្ឋប្បវេណី៖** "បើការពិភាក្សារវាងសហសន្តតិជនចំពោះការបែងចែកមត៌កមិនបានសម្រេច ឬបើពុំអាចពិភាក្សាបានទេ សហសន្តតិជនណាម្នាក់អាចដាក់ពាក្យសុំទៅតុលាការឱ្យធ្វើការបែងចែកមត៌កនោះបាន"។

# គ-វិសាលភាពនៃក្រមនីតិវិធីរដ្ឋប្បវេណី

លើកលែងតែក្នុងករណីដែលច្បាប់ផ្សេងបានកំណត់ពិសេស នីតិវិធីដែលទាក់ទងទៅនឹងបណ្ដឹងរដ្ឋប្បវេណី ត្រូវដោះស្រាយតាមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលក្នុងនោះមានបណ្ដឹងទាក់ទងនឹងសន្តិកម្មមួយចំនួនដូចខាងក្រោម៖

-សមត្ថកិច្ចសាលាជម្រះក្ដីចំពោះបណ្ដឹងទាក់ទងនឹងមត៌ក (**មាត្រា៩ ចំណុច ឈ ក្រមនីតិវិធី**)

-បណ្ដឹងទាមទារឱ្យបញ្ឈប់ និងបង្ការការរារាំងដោយផ្អែកលើកម្មសិទ្ធិ (**មាត្រា ១៥៩**)

-បណ្ដឹងទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង (**មាត្រា ១២៣៥**)

-បណ្ដឹងទាមទាររបស់សន្តតិជនដែលត្រូវបានទទួលស្គាល់ក្រោយការបែងចែកមត៌ក (**មាត្រា ១២៧៤**)

-បណ្ដឹងទាមទារឱ្យធ្វើបដិទាននូវសន្តតិកម្ម (**មាត្រា ១៣០២**)

-បណ្ដឹងទាមទារឱ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍ (**មាត្រា១១៧០**)

# ឃ-ការស្រាវជ្រាវ និងការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ

## ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

**មាត្រា ១៤ (ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ)** បានចែងថា នៅក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល តុលាការអាចយកអង្គហេតុដែលមិនបានអះអាងដោយភាគីមកធ្វើជាមូលដ្ឋាននៃសាលក្រមបាន។ ក្នុងករណីនេះ តុលាការត្រូវសួរមតិពីភាគីអំពីអង្គហេតុនោះ។

## ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

**មាត្រា ៨ (ការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ)** បានចែងថា តុលាការអាចពិនិត្យភស្តុតាងចំពោះបញ្ហាដែលទាក់ទងនឹងសមត្ថកិច្ចដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន។

**មាត្រា ២៧ (ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ និងការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ)** បានចែងថា តុលាការអាចយកអង្គហេតុដែលមិនបានអះអាងដោយអ្នកដាក់ពាក្យសុំ ឬដោយភាគីម្ខាងទៀត មកធ្វើជាមូលដ្ឋាននៃដីកាសម្រេចបាន។ ប្រសិនបើយល់ឃើញថា ចាំបាច់ តុលាការត្រូវធ្វើការស្រាវជ្រាវអង្គហេតុ និងធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ។

## ក្រមនីតិវិធីរដ្ឋប្បវេណី

**មាត្រា ៩០ (សិទ្ធិឱ្យបំភ្លឺ ជាអាទិ៍)** បានចែងថា ដើម្បីឱ្យចំណុចនៃអង្គហេតុ និងអង្គច្បាប់ដែលទាក់ទងនឹងបណ្ដឹង មានភាពច្បាស់លាស់ តុលាការអាចសាកសួរភាគី ឬឱ្យភាគីអះអាង ឬបញ្ជាក់ភស្តុតាងចំពោះចំណុចនោះនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬការទាញហេតុផលដោយផ្ទាល់មាត់បាន។

**មាត្រា ១២៤ កថាខណ្ឌទី២ (ការពិនិត្យភស្តុតាង)** បានចែងថា ប្រសិនបើតុលាការពុំអាចសម្រេចថា ត្រូវទទួលស្គាល់ ឬមិនទទួលស្គាល់នូវការអះអាងអំពីអង្គហេតុ ដោយភស្តុតាងដែលគូភាគបានស្នើសុំឱ្យពិនិត្យ ឬបើយល់ឃើញថា មានភាពចាំបាច់ផ្សេងទៀត នោះតុលាការអាចយកមកធ្វើការពិនិត្យភស្តុតាង ដោយឆន្ទានុសិទ្ធិបាន។

**មាត្រា ៧៧ (ការបញ្ចូលការទាមទារច្រើនចំណុចទៅក្នុងបណ្តឹងតែមួយ)** បានចែងថា ការទាមទារច្រើនចំណុច អាចយកមកបញ្ចូលក្នុងបណ្តឹងតែមួយបាន លុះត្រាតែការទាមទារនោះដោះស្រាយដោយនីតិវិធីប្រភេទដូចគ្នា។

# ការបែងចែកមត៌ក

## ១-របបសន្តតិកម្ម

របបសន្តតិកម្ម មាន ២ ប្រភេទ គឺ គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ និងគោលការណ៍ជម្រះបញ្ជី។

ក្រមរដ្ឋប្បវេណីយើង ជ្រើសរើសយក**គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ**។ ជាក់ស្តែង មាត្រា ១១៤៧ កថា.១ បានចែងថា សន្តតិជន ត្រូវទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចទាំងអស់ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជន ចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្ម។

**មាត្រា ១១៤៨** នៃក្រមរដ្ឋប្បវេណី បានចែងថា ប្រសិនបើមានសន្តតិជនច្រើននាក់ សហសន្តតិជនម្នាក់ៗ ត្រូវទទួលបន្តនូវសិទ្ធិ និងករណីយកិច្ច តាមសមាមាត្រនៃចំណែកមត៌កនោះ។

**សម្គាល់៖**

ទាក់ទងនឹងអចលនវត្ថុ ក្នុងករណីមានការព្រមព្រៀងគ្នា សហសន្តតិជន អាចដាក់ពាក្យសុំទៅរដ្ឋបាលសុរិយោដី ដើម្បីចុះបញ្ជីផ្ទេរកម្មសិទ្ធិ ឬចំណែកកម្មសិទ្ធិអវិភាគ ដោយមិនចាំបាច់មានសេចក្តីសម្រេចពីតុលាការនោះទេ អនុលោមតាមប្រការ ១០ ប្រការ ២៦ និងប្រការ ២៨ នៃប្រកាសអន្តរក្រសួងលេខ ៣០ កយ.ដនស.ប្រក/១៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី។

ផ្ទុយទៅវិញ ក្នុងការអនុវត្តជាក់ស្តែង រដ្ឋបាលសុរិយោដី និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុមិនអនុវត្តតាមស្មារតីនៃបទប្បញ្ញត្តិនេះទេ តែងតែទាមទារឱ្យមានការសម្រេចរបស់តុលាការជាមុនសិន។

# ការបែងចែកមត៌ក (បន្ត)

- **មាត្រា ១២៧០ កថា.១ (ការបែងចែកដោយតុលាការ)** បានចែងថា បើការពិភាក្សារវាងសហសន្តតិជន ចំពោះការបែងចែកមត៌ក ពុំបានសម្រេច ឬបើពុំអាចពិភាក្សាបានទេ សហសន្តតិជនណាម្នាក់ អាចដាក់ពាក្យសុំទៅតុលាការឱ្យធ្វើការបែងចែកមត៌កនោះបាន។

- ករណីមាត្រា១២៧០ កថាខណ្ឌទី១ នេះ គឺករណីដែលមានវិវាទតែទៅលើវិធីបែងចែកមត៌កប៉ុណ្ណោះ។ (ករណីនេះ មិនមានវិវាទលើការទទួលស្គាល់សន្តតិជន និងមិនមានវិវាទលើការទទួលស្គាល់ទ្រព្យជាសន្តតិកម្ម)

- ករណីភាគីមានវិវាទលើការទាមទារទទួលស្គាល់ជាសន្តតិជន ឬមានវិវាទអំពីសិទ្ធិលើទ្រព្យជាមូលដ្ឋាននៃសន្តតិកម្ម ត្រូវដោះស្រាយតាមប្រភេទនីតិវិធីផ្សេងទៀត ពោលគឺមិនអាចដោះស្រាយតាមនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងបានទេ។

## ២-គោលការណ៍នៃការបែងចែកមត៌ក

**មាត្រា ១១៤៨** នៃក្រមរដ្ឋប្បវេណី បានចែងថា ប្រសិនបើមានសន្តតិជនច្រើននាក់ សហសន្តតិជនម្នាក់ៗ ត្រូវទទួលបន្តនូវសិទ្ធិ និងករណីយកិច្ច តាមសមាមាត្រនៃចំណែកមរតកនោះ។

ការបែងចែកមត៌ក ត្រូវធ្វើការពិចារណាលើទ្រព្យសកម្ម និងបំណុល, អត្ថិភាពនៃសន្តតិជន, អត្ថិភាពនៃម្ចាស់បំណុល និងត្រូវវាយតម្លៃមត៌ក ដើម្បីទៅរកភាគបម្រុង។

## ៣-របៀបគណនាមត៌ក

ដើម្បីអាចគណនាចំណែកមត៌កសន្តតិជនម្នាក់ ត្រូវ៖

-គណនាចំនួនមត៌កសរុបរបស់មតកជន

-កំណត់ចំនួនសន្តតិជន

-ធ្វើផលចែកចំនួនមត៌កសរុបនឹងចំនួនសន្តតិជន

## ៤-វិធីបែងចែក

-ការបែងចែកតាមការបង់ប្រាក់សម្រួល (មាត្រា ១២៦៧ កថា.២)

-ការបែងចែកដោយប្តូរជាប្រាក់ (មាត្រា ១២៧១)

-ការបែងចែកទៅជាទ្រព្យអវិភាគ (មាត្រា ២០២)

-ការបែងចែកតាមវិធីបែងចែកវត្ថុកម្មសិទ្ធិអវិភាគ (មាត្រា ២១២)

❖ កត្តាត្រូវពិចារណា

-សិទ្ធិអាទិភាពរបស់សហព័ទ្ធ (មាត្រា ១២៦៨)

-សំណងនៃកាតព្វកិច្ចរបស់មតកជន (មាត្រា ១២៦៩)

-ទំនៀមទម្លាប់ក្នុងតំបន់ និងមតិលើសពីពាក់កណ្តាលរបស់សហសន្តតិជន (មាត្រា ១២៧០ កថា.២)

## ៥-ប្រព័ន្ធនៃភាគបម្រុង

-អ្នកមានសិទ្ធិលើភាគបម្រុង (មាត្រា ១២៣០)

-របៀបនៃការគណនាភាគបម្រុង

- ✓ គណនាសមាមាត្រានៃភាគបម្រុងរបស់សន្តតិជន (មាត្រា ១២៣០)
- ✓ គណនាទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង (មាត្រា ១២៣១)
- ✓ គណនានូវអត្ថិភាព ឬនត្ថិភាពនៃការបំពានភាគបម្រុង និងចំនួនទឹកប្រាក់ដែលបានបំពាន (មាត្រា ១២៣៤)

-ក្នុងករណីមានអត្ថិភាពនៃការបំពានភាគបម្រុង ត្រូវអនុវត្តសិទ្ធិតាមមាត្រា ១២៣៥ (បណ្តឹងទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង) តាមនីតិវិធីបណ្តឹងធម្មតា។

# បញ្ហាទី១ ការទាមទារឱ្យទទួលស្គាល់ជាសន្តតិជន

- ការទាមទារឱ្យទទួលស្គាល់ជាសន្តតិជន នៅក្នុងនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង គឺជាការទាមទារដែលផ្ទុយនឹងច្បាប់ ព្រោះថា ការទាមទារនេះ ពុំមានកំណត់ក្នុងផ្នែកនីមួយៗនៃតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ផ្នែកតាមមាត្រា ៣ នៃច្បាប់នេះ។

- ការទាមទារឱ្យទទួលស្គាល់ជាសន្តតិជន អាចធ្វើបានក្នុងនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ប៉ុន្តែ ត្រូវកែខ្លឹមសារនៃការទាមទារនេះ ទៅជាការទាមទារឱ្យទទួលស្គាល់កូន តាមបញ្ញត្តិមាត្រា ១០០១ នៃក្រមរដ្ឋប្បវេណី ជាអាទិ៍ ផ្អែកតាមមាត្រា ៣ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។

# បញ្ហាទី២ ភាពមិនអាចបញ្ចូលគ្នាបាននូវការទាមទារ ឱ្យទទួលស្គាល់សន្តតិជន និងការបែងចែកមត៌ក

- ផ្អែកតាមមាត្រា ៧៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ការទាមទារច្រើនចំណុច អាចយកមកបញ្ចូលក្នុងបណ្តឹងតែមួយបាន លុះត្រាតែការទាមទារនោះដោះស្រាយដោយនីតិវិធីប្រភេទដូចគ្នា។
- ការទាមទារឱ្យទទួលស្គាល់សន្តតិជន ជាការទាមទារដោយប្រើប្រាស់នីតិវិធីនៃច្បាប់ស្តីពីនីតិវិធីបណ្តឹងពាក់ព័ន្ធនឹងឋានៈបុគ្គល។
- ការទាមទារបែងចែកមត៌ក ផ្អែកតាមកថាខណ្ឌទី១ នៃមាត្រា១២៧០ នៃក្រមរដ្ឋប្បវេណី ជាការទាមទារដែលត្រូវប្រើប្រាស់នីតិវិធីនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។

# បញ្ហាទី៣ ករណីមានវិវាទអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិនៃទ្រព្យដែលជាកម្មវត្ថុនៃសន្តតិកម្ម

- តុលាការ មិនអាចសម្រេចអំពីវិវាទនេះ ក្នុងនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងបានឡើយ ព្រោះថា វិវាទនេះ ពុំមានកំណត់ក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។

- វិវាទនេះ ត្រូវដោះស្រាយតាមក្រមនីតិវិធីរដ្ឋប្បវេណី។ ក្នុងករណីដែលតុលាការទទួលស្គាល់ថា ទ្រព្យជាកម្មសិទ្ធិរបស់មកតជន ទើបសន្តតិជន អាចទាមទារឱ្យធ្វើការបែងចែង តាមនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងបាន។

## បញ្ហាទី៤ ការកំណត់ទ្រព្យដែលជាសន្តតិកម្ម

### ប្រវត្តិដីធ្លីក្នុងសម័យរដ្ឋកម្ពុជា(ក្រុមសាមគ្គីបង្កបង្កើនផល)

មាត្រា ៣ នៃអនុក្រឹត្យស្តីពីការប្រើប្រាស់ដីធ្លីកសិកម្ម (ឆ្នាំ១៩៨៥) បានចែងថា ចំនួនផ្ទៃដីដែលប្រគល់ឱ្យក្រុមសាមគ្គីបង្កបង្កើនផល ត្រូវគិតទៅតាមមធ្យមភាគនៃចំនួនប្រជាជនទូទៅក្នុងឃុំ សង្កាត់រួមទាំងអ្នកចូលរួមបម្រើកងទ័ព នគរបាល កម្មាភិបាល កម្មករ បុគ្គលិករដ្ឋ និងជនពលីដើម្បីបដិវត្តន៍ដែលមានឈ្មោះក្នុងបញ្ជីជំរឿនគ្រួសារនៅក្នុងមូលដ្ឋាន។

មាត្រា ៤ កថា.១ នៃអនុក្រឹត្យស្តីពីការផ្តល់កម្មសិទ្ធិលើផ្ទះជូនពលរដ្ឋកម្ពុជា បានចែងថា មេក្រុមគ្រួសារដែលកំពុងរស់នៅលើលំនៅឋាន ដែលឋិតនៅក្រោមការគ្រប់គ្រងរបស់ឃុំសង្កាត់ណាត្រូវធ្វើលិខិតសុំកាន់កាប់កម្មសិទ្ធិលើលំនៅឋានដែល ខ្លួនរស់នៅតាមរយៈរដ្ឋអំណាចឃុំ សង្កាត់នោះ។

មាត្រា ១៣៧ នៃក្រមរដ្ឋប្បវេណី៖ នៅពេលដែលបានចុះបញ្ជីសិទ្ធិក្នុងបញ្ជីអចលនវត្ថុហើយ សិទ្ធិនេះត្រូវបានសន្មតថា ជាសិទ្ធិរបស់អ្នកដែលមានឈ្មោះនៅក្នុងបញ្ជីនោះ។

# ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី សម័យរដ្ឋកម្ពុជា <u>បែងចែកទៅតាមចំនួនសមាជិកគ្រួសារនីមួយៗ</u>



ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ ដីធ្លី

ខ្ញុំបាទ នាងខ្ញុំឈ្មោះ ______ ភេទ ______ អាយុ ______ សញ្ជាតិ ______ ប្រពន្ធ ប្តី ឈ្មោះ ______ សមាជិកក្នុងគ្រួសារសរុប 6 នាក់ ទីលំនៅ។ ភូមិ ______ ឃុំ ______ ស្រុក ______ ខេត្ត ______ ។

សូមគោរពជូន

សមមិត្តប្រធានគណៈកម្មាធិការប្រជាជនស្រុក ______

តាមរយៈ
- សមមិត្តប្រធានភូមិ ______
- សមមិត្តប្រធានគណៈកម្មាធិការប្រជាជនឃុំ ______
- សមមិត្តប្រធានការិយាល័យកសិកម្មស្រុក ______

កម្មវត្ថុ : សំណើសុំកាន់កាប់ប្រើប្រាស់ ដីធ្លី

ដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ នាងខ្ញុំ បានកាន់កាប់ប្រើប្រាស់ដី(១) ______ នៅភូមិ ______ ឃុំ ______ ស្រុក ______ ខេត្ត ______ ដែលមានទំហំ 1650 $m^2$ ចាប់ពីឆ្នាំ ១៩79 មកទល់បច្ចុប្បន្ន ។

ដីនេះ មានព្រំប្រទល់

- ខាងជើងទល់នឹង ______
- ខាងត្បូងទល់នឹង ______
- ខាងកើតទល់នឹង ______
- ខាងលិចទល់នឹង ______

អាស្រ័យហេតុនេះ សូមសមមិត្តប្រធានគណៈកម្មាធិការប្រជាជនស្រុក ______ មេត្តាពិនិត្យនិងសំរេចចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដល់ខ្ញុំបាទ នាងខ្ញុំ ដោយអនុគ្រោះ ។ ខ្ញុំបាទ នាងខ្ញុំ សូមប្តេជ្ញាថាអនុវត្តតាមរាល់កាតព្វកិច្ច និង បទបញ្ជាផ្សេង ៗ ដែលរដ្ឋបានកំណត់ ។

ធ្វើនៅ ______ ថ្ងៃទី 5 ខែ 6 ឆ្នាំ ១៩90

សេចក្តីបញ្ជាក់របស់ប្រធានភូមិ

... 1979 ...

ហត្ថលេខា ឬ ស្នាមមេដៃ

លេខ ______

បានឃើញ និង បញ្ជូនមកសមមិត្ត ប្រធានការិយាល័យកសិកម្មស្រុក ______ ដើម្បីពិនិត្យ និង សំរេចតាមការគួរ

______ ថ្ងៃទី ______ ខែ ______ ឆ្នាំ១៩ ______

ប្រធានគណៈកម្មាធិការប្រជាជនឃុំ ______

(១) - ដីសំរាប់សង់លំនៅឋាន ឬដីស្រែ ឬដីចំការ ។ បើដីសង់លំនៅឋាន ពាក្យស្នើសុំនេះត្រូវបញ្ជូនទៅ គណៈកម្មាធិការប្រជាជន ខេត្ត ក្រុង

# ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី <u>បែងចែកទៅតាមចំនួនសមាជិកគ្រួសារនីមួយៗ</u>





ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ ដីធ្លី

ខ្ញុំបាទ នាងខ្ញុំឈ្មោះ ____ ភេទ ____ អាយុ ____ សញ្ជាតិ ____
ប្រពន្ធ ប្ដី ឈ្មោះ ____ សមាជិកក្នុងគ្រួសារសរុប 6 នាក់ ទីលំនៅ។ ភូមិ ____
ឃុំ ____ ស្រុក ____ ខេត្ត ____ ,

សូមគោរពជូន

សមមិត្តប្រធានគណៈកម្មាធិការប្រជាជនស្រុក ____

តាមរយៈ: – សមមិត្តប្រធានភូមិ ____
– សមមិត្តប្រធានគណៈកម្មាធិការប្រជាជនឃុំ ____
– សមមិត្តប្រធានការិយាល័យកសិកម្មស្រុក ____

កម្មវត្ថុ : សំណើសុំកាន់កាប់ប្រើប្រាស់ ដីធ្លី

ដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ នាងខ្ញុំ បានកាន់កាប់ប្រើប្រាស់ដី(១) ____
____ នៅភូមិ ____ ឃុំ ____ ស្រុក ____
ខេត្ត ____ ដែលមានទំហំ 1650 m² ____ ចាប់ពីឆ្នាំ ១៩79 មកទល់បច្ចុប្បន្ន ។
ដីនេះ មានព្រំប្រទល់

# ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី បែងចែកទៅតាមចំនួនសមាជិកគ្រួសារនីមួយៗ





ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ ដីធ្លី

ខ្ញុំបាទ នាងខ្ញុំឈ្មោះ ______ ភេទ ______ អាយុ ______ សញ្ជាតិ ______

ប្រពន្ធ ប្តី ឈ្មោះ ______ សមាជិកក្នុងគ្រួសារសរុប 03 នាក់ ទីលំនៅៗ ភូមិ ______

ឃុំ ______ ស្រុក ______ ខេត្ត ______

សូមគោរពជូន

សមមិត្តប្រធានគណៈកម្មាធិការប្រជាជនស្រុក ______

តាមរយៈ: – សមមិត្តប្រធានភូមិ ______

– សមមិត្តប្រធានគណៈកម្មាធិការប្រជាជនឃុំ ______

– សមមិត្តប្រធានការិយាល័យកសិកម្មស្រុក ______

កម្មវត្ថុ : សំណើសុំកាន់កាប់ប្រើប្រាស់ ដីធ្លី

ដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ នាងខ្ញុំ បានកាន់កាប់ប្រើប្រាស់ដី(១) ______

______ នៅភូមិ ______ ឃុំ ______ ស្រុក ______

ខេត្ត ______ ដែលមានទំហំ ______ ចាប់ពីឆ្នាំ ១៩ ______ មកទល់បច្ចុប្បន្ន ។

ដីនេះ មានព្រំប្រទល់ :

# សាលក្រមលេខ ០៣៣ "ណ" ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកណ្ដាល



**សេចក្តីសម្រេចបញ្ចប់**

**១-ទទួលស្គាល់** ១.ឈ្មោះ យឹម សុវត្ថិ, ២.ឈ្មោះ យឹម សុចង, ៣.ឈ្មោះ យឹម សុគន្ធ, ៤.ឈ្មោះ យឹម សុវណ្ណរិទ្ធ, ៥.ឈ្មោះ យឹម វិរ៉ាកា, ៧.ឈ្មោះ យឹម វិចិត្រ, ៧.ឈ្មោះ សុទ្ធា តាក់ និង៨.ឈ្មោះ ពៅ សារ៉ាង ជាសហសន្តិជន នៃមរតកជនឈ្មោះ ១.យ៉ុង សុទ្ធា ហៅ មៅ សុទ្ធា, ២.ឈ្មោះ យ៉ុង ធុល, ៣.ឈ្មោះ យុង (យ៉ុង) យ៉ឺន ហៅ យង់ យ៉ឺន។

**២-ច្រានចោលការទាមទារ** ឱ្យបែងចែកចំណែកមរតក នៃដីទំហំចំនួន ៧២៥ (ប្រាំពីររយម្ភៃប្រាំ) ម៉ែត្រការ៉េ ដោយមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ១៨៣៧/៨៩ ក.ត ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៨៩ របស់សហដើមចោទ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហដើមចោទ។

សាលក្រមនេះប្រកាសជាសាធារណៈ នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២៤ ចំពោះមុខសហដើមចោទ និងសហចុងចម្លើយ បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៤កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

ខេត្តកណ្ដាល ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២៤

**បានឃើញ**

**ចៅក្រម**

**ក្រឡាបញ្ជី**

[redacted]

[redacted]

អាសយដ្ឋាន៖ ផ្លូវជាតិលេខ២ ភូមិតាខ្មៅ២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល

ទំព័រ ៦នៃ ៦



ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ ដីធ្លី

ខ្ញុំបាទ នាងខ្ញុំឈ្មោះ ____ ភេទ ____ អាយុ ____ សញ្ជាតិ ____

ប្រពន្ធ ឬ ប្តី ឈ្មោះ ____ សមាជិកក្នុងគ្រួសារសរុប ____ នាក់ រស់នៅភូមិ ____

ឃុំ ____ ស្រុក ____ ខេត្ត ____។

សូមគោរពជូន

សមមិត្តប្រធានគណៈកម្មាធិការប្រជាជនស្រុក ____

តាមរយៈ:
– សមមិត្តប្រធានភូមិ ____
– សមមិត្តប្រធានគណៈកម្មាធិការប្រជាជនឃុំ ____
– សមមិត្តប្រធានការិយាល័យកសិកម្មស្រុក ____

កម្មវត្ថុ : សំណើសុំកាន់កាប់ប្រើប្រាស់ ដីធ្លី

ដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ នាងខ្ញុំ បានកាន់កាប់ប្រើប្រាស់ដី(១) ____ នៅភូមិ ____ ឃុំ ____ ស្រុក ____ ខេត្ត ____ ដែលមានទំហំ ____ ចាប់ពីឆ្នាំ ១៩__ មកទល់បច្ចុប្បន្ន។

ព្រំប្រទល់

– ខាងជើងទល់នឹង ____
– ខាងត្បូងទល់នឹង ____
– ខាងកើតទល់នឹង ____
– ខាងលិចទល់នឹង ____

អាស្រ័យហេតុនេះ សូមសមមិត្តប្រធានគណៈកម្មាធិការប្រជាជនស្រុក ____ មេត្តាពិនិត្យនិងសំរេចចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដល់ខ្ញុំបាទ នាងខ្ញុំ ដោយអនុគ្រោះ ។ ខ្ញុំបាទ នាងខ្ញុំ សូមប្តេជ្ញាថាអនុវត្តតាមរាល់កាតព្វកិច្ច និង បទបញ្ញាផ្សេងៗ ដែលរដ្ឋបានកំណត់ ។

ធ្វើនៅ ____ ថ្ងៃទី 11 ខែ 12 ឆ្នាំ ១៩ 89

ហត្ថលេខា ឬ ស្នាមមេដៃ

សេចក្តីបញ្ជាក់របស់ប្រធានភូមិ

លេខ 1837/____

បានឃើញ និង បញ្ជូនមកសមមិត្ត ប្រធានការិយាល័យកសិកម្មស្រុក ____ ដើម្បីពិនិត្យ និង សំរេចតាមការគួរ

____ ថ្ងៃទី ____ ខែ 12 ឆ្នាំ១៩ 89

ប្រធានគណៈកម្មាធិការប្រជាជនឃុំ

(១) - ដីសំរាប់សង់លំនៅឋាន ឬដីស្រែ ឬដីចំការ ។ បើដីសំរាប់សង់លំនៅឋាន ពាក្យស្នើសុំនេះត្រូវបញ្ជូនទៅ គណៈកម្មាធិការប្រជាជន ខេត្ត ក្រុង

## បញ្ហាទី៥ ការបែងចែកដោយមិនបានគណនាទ្រព្យសរុប និងភាគបម្រុង

ការបែងចែកមត៌ក ត្រូវធ្វើការពិចារណាទ្រព្យសកម្ម និងបំណុល អត្ថិភាពនៃសន្តតិជន អត្ថិភាពនៃម្ចាស់បំណុល និងវាយតម្លៃមត៌ក ដើម្បីទៅរកភាគបម្រុង។

មាត្រា១២៦៩ (សំណងនៃកាតព្វកិច្ចរបស់មតកជន ជាអាទិ៍) បើមតកជនមានកាតព្វកិច្ចសហសន្តតិជនត្រូវបែងចែកមត៌ក ដោយពិចារណាពីការណ៍ថា ខ្លួនត្រូវសងកាតព្វកិច្ចនោះ និងមិនអាចប្តូរភោគបន្ទុកនៃកាតព្វកិច្ចនោះ ដោយគ្មានការយល់ព្រមពីសំណាក់ម្ចាស់បំណុលឡើយ។

មាត្រា **១២៦៩** នៃក្រមរដ្ឋប្បវេណី មិនហាមមិនឱ្យយកបំណុលមកបែងចែកទេ គឺបំណុលត្រូវបែងចែកទៅតាមសមាមាត្រានៃចំណែកមត៌ករបស់សន្តតិជនម្នាក់ៗ។

# បញ្ហាទី៦ ការសម្រេចសេចក្តីដែលមិនអាចបញ្ចប់វិវាទបាន

## ដីកាសម្រេចលេខ ០៣៥ ន.ម.ប.ឈ/២០ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកណ្តាល

**ហេតុដូច្នេះសម្រេច**

២. បែងចែកដី (អចលនវត្ថុ) ដែលមានក្បាលដីលេខ ៣១ ទំហំ ១៦៥ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិស្វាយជ្រូរ ឃុំកោះខែល ស្រុកស្អាង ខេតកណ្តាល ដែលមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៩០ ជាប្រាំមួយចំណែក ដោយឈ្មោះ **ឡាច ស៊ាង** (សុត ស្រ៊ាង) ទទួលបានចំណែក ២៦,៦៦ % (ភាគរយ) នៃអចលនវត្ថុ ឈ្មោះ **ឡាច សាំងរ៉ុង** ទទួលបានចំណែក ២៦,៦៦ % (ភាគរយ) នៃអចលនវត្ថុ ឈ្មោះ **ឡាច សុខ** ទទួលបានចំណែក ២៦,៦៦ % (ភាគរយ) នៃអចលនវត្ថុ ឈ្មោះ **ឡាច តិចលី** ទទួលបានចំណែក ៦,៦៦ % (ភាគរយ) នៃអចលនវត្ថុ ឈ្មោះ **ឡាច ឈុន** ទទួលបានចំណែក ៦,៦៦ % (ភាគរយ) នៃអចលនវត្ថុ និង ឈ្មោះ **សៀ គីមសាំង** ទទួលបានចំណែក ៦,៦៦ % (ភាគរយ) នៃអចលនវត្ថុ ។

៣. បែងចែកមរតកជាអចលនវត្ថុដែលមានចំនួន ៦ កន្លែង ដោយក្នុងមួយកន្លែងៗ (មួយទីតាំង) ត្រូវបែងចែកជា ៦ ចំណែកស្មើគ្នា ដើម្បីប្រគល់ឱ្យសន្តតិជនឈ្មោះ **ឡាច តិចលី** មួយចំណែក ឈ្មោះ **ឡាច ឈុន** មួយចំណែក ឈ្មោះ **សៀ គីមសាំង** មួយចំណែក ឈ្មោះ **ឡាច សាំងរ៉ុង** (ឡាច រ៉ុង) មួយចំណែក ឈ្មោះ **ឡាច ស៊ាង** (សុត ស្រ៊ាង) មួយចំណែក និង ឈ្មោះ **ឡាច សុខ** មួយចំណែក នូវអចលនវត្ថុ មានអត្តសញ្ញាណដូចខាងក្រោម៖

៣.១. ដីចំការទំហំ ១៥២០ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិស្វាយជ្រូរ ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្តាល ដែលមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៩០

## បញ្ហាទី៧ មតកសាសន៍ដោយលិខិតយថាភូតដែលធ្វើឡើងដោយសារការី

ទម្រង់នៃមតកសាសន៍ រួមមាន មតកសាសន៍ដោយលិខិតយថាភូត, មតកសាសន៍ដោយលិខិតឯកជន, មតកសាសន៍ដោយលិខិតសម្ងាត់, មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត, មតកសាសន៍នៃជនដែលត្រូវឃុំឃាំង ជាអាទិ៍។

**មាត្រា ១១៩៤ កថា.១ (ពេលដែលមតកសាសន៍បង្កើតអានុភាព)** មតកសាសន៍ត្រូវបង្កើតអានុភាព ចាប់ពីពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព។

មតកសាសន៍ក្រៅពីមតកសាសន៍ដោយលិខិតយថាភូត អ្នកដែលបានរក្សាទុក ឬអ្នកដែលបានរកឃើញនូវលិខិតមតកសាសន៍ ត្រូវតែដាក់ពាក្យសុំឱ្យពិនិត្យបញ្ជាក់នៅតុលាការ ផ្អែកតាមមាត្រា ១២១៣ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។

- **មាត្រា ១១៧០ កឋ.១ (ភាពចាំបាច់នៃទម្រង់មតកសាសន៍)** មតកសាសន៍ ពុំអាចធ្វើបានឡើយ បើពុំផ្អែកតាមទម្រង់ដែលបានកំណត់ក្នុងក្រមនេះទេ។
- **មាត្រា ១១៧៣ (មតកសាសន៍ដោយលិខិតយថាភូត)** មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើងដោយម្ចាស់បណ្តាំ នៅចំពោះមុខសារការី តាមទម្រង់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ ខាងក្រោមនេះ។
- **មាត្រា ១១៨២ (ការកំណត់ចំណែកមត៌ក)** មតកជនអាចកំណត់ចំណែកមត៌ក របស់សហសន្តតិជនតាមមតកសាសន៍ ឬអាចបង្ហាញឆន្ទៈផ្ទុយពីបញ្ញត្តិនៃមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) នៃក្រមនេះ ស្តីពីចំណែកមត៌ករបស់បុគ្គលដែលបានទទួលផលប្រយោជន៍ពិសេសបាន។ ប៉ុន្តែ ការកំណត់ចំណែកមត៌កដែលបំពានភាគបម្រុងត្រូវអនុលោមតាមបញ្ញត្តិស្តីពីភាគបម្រុង។

- **មាត្រា ១១៩៤ (ពេលដែលមតកសាសន៍បង្កើតអានុភាព)** មតកសាសន៍ ត្រូវបង្កើតអានុភាព ចាប់ពីពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព។
- **មាត្រា ១១៩៥ កថា.១ (អានុភាពនៃការកំណត់ចំណែកមត៌ក ជាអាទិ៍)** បើមតកជនបាន កំណត់ចំណែកមត៌ក ឬវិធីបែងចែកមត៌ក ដោយធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬច្រើន ឱ្យចំពោះសន្តតិជនតែម្នាក់ ឬច្រើននាក់ ដោយមតកសាសន៍ ទ្រព្យសម្បត្តិជាក់លាក់នោះ ត្រូវផ្លាក់ទៅសន្តតិជនដែលនឹងត្រូវទទួលទ្រព្យសម្បត្តិនោះដោយស្វ័យប្រវត្តិ ព្រមគ្នានឹងពេល មតកសាសន៍នោះបង្កើតអានុភាព។

# ដីកាសម្រេចលេខ ១៨២ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ

## អង្គហេតុ

លោក **ក** (មតកជន) មានកូនបង្កើតចំនួន ៦នាក់ រួមាន A , B , C , D ,  E , F ហើយលោក **ក** មានទ្រព្យសម្បត្តិជាអចលនវត្ថុចំនួន ២៥កន្លែង។ លោក **ក** បានបន្សល់ទុកនូវមតកសាសន៍ដែលបានធ្វើនៅប្រទេសសិង្ហបុរី នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១២ **ចំពោះមុខសារការី**នៃព្រះរាជាណាចក្រកម្ពុជា និងសាក្សីចំនួន ២រូប។ នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១២ លោក **ក** បានទទួលមរណភាព។

នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៦ A , D , F , REN-KUAN JERMY KUO (កូនរបស់ B) បានដាក់ពាក្យសុំបែងចែកមត៌កទៅសាលាដំបូងរាជធានីភ្នំពេញ។

# ចំណាត់ការតុលាការ

**-សាលាដំបូងរាជធានីភ្នំពេញ៖** បានចេញដីកាសម្រេចលេខ ១៨២ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ សម្រេច **បែងចែកទ្រព្យទាំង ២៥កន្លែង ជា ៦ ចំណែកស្មើៗគ្នា ទៅឱ្យសហសន្តតិជនទាំង ៦នាក់ ខាងលើ ដោយសំអាងហេតុថា *មតកសាសន៍ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១២ របស់លោក ក ពុំមានសមភាពក្នុងចំណោម សន្តតិជនទាំងអស់ឡើយ*។** តុលាការគប្បីធ្វើតាមមាត្រា ១១៥៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។

*B និង E ប្តឹងជំទាស់នឹងដីកាសម្រេចខាងលើ។*

**-សាលាឧទ្ធរណ៍ភ្នំពេញ** ចេញដីកាសម្រេចលេខ ៣៥ក្រ VI(ឃ) ដកស ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ សម្រេច តម្កល់ដីកាសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញ។

*B និង E ប្ដឹងទាមទារឱ្យជំនុំជម្រះសារជាថ្មី។*

-**សាលាឧទ្ធរណ៍ភ្នំពេញ** ចេញដីកាសម្រេចលេខ ០១ (ក្រ.VIច) ដកស ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ ២០២០ សម្រេច ប្រានចោលពាក្យសុំឱ្យជំនុំជម្រះសាជាថ្មី និងតម្កល់ដីកាសម្រេចរបស់សាលាឧទ្ធរណ៍។

*B និង E ប្ដឹងជំទាស់ទៅតុលាការកំពូល។*

-**តុលាការកំពូល** ចេញដីកាសម្រេចលេខ ០៤ ដ.ស (ថ) ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០២១ សម្រេចៈ

១.ទទួលពាក្យបណ្ដឹងជំទាស់របស់ B និង

២.បដិសេធ

- ដីកាសម្រេចលេខ ១៨២ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧
- ដីកាសម្រេចលេខ ៣៥ក្រ VI(ឃ) ដកស ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧
- ដីកាសម្រេចលេខ ០១ (ក្រ.VIច) ដកស ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២០។

៣.ប្រានចោលពាក្យសុំដីកាសម្រេចបែងចែកមត៌ករបស់មតកជន **ក** ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៦ របស់អ្នកដាក់ពាក្យសុំ។

**តុលាការកំពូលសំអាងថា** *ករណីសន្តតិកម្មតាមមតកសាសន៍ដោយលិខិតយថាភូត ធ្វើឡើងដោយម្ចាស់បណ្តាំនៅចំពោះមុខសារការី តាមទម្រង់ដែលកំណត់ក្នុងមាត្រា ១១៧៣ នៃក្រមរដ្ឋប្បវេណី។ ដូច្នេះ មតកសាសន៍នេះ ត្រូវបង្កើតអានុភាពចាប់ពីពេលដែលម្ចាស់បបណ្តាំបានទទួលមរណភាពតាមមាត្រា ១១៩៤ នៃក្រមរដ្ឋប្បវេណី។ម្យ៉ាងទៀត តាមមាត្រា ១១៨២ នៃក្រមរដ្ឋប្បវេណី កថាខណ្ឌទី១ បានចែងថា "មតកជនអាចកំណត់ចំណែកមត៌ករបស់សហសន្តតិជនតាមមតកសាសន៍...បាន។ ប៉ុន្តែការកំណត់ចំណែកមត៌កដែលបំពានភាគបម្រុង ត្រូវអនុលោមតាមបញ្ញត្តិស្តីពីភាគបម្រុង។" ដូច្នេះ សន្តតិជនដែលមានសិទ្ធិលើភាគបម្រុងអាចទាមទារភាគបម្រុងបាន តាមមាត្រា ១២៣០ នៃក្រមរដ្ឋប្បវេណី ដែលការទាមទារនេះ ត្រូវអនុលោមតាមនីតិវិធីបណ្តឹង។*

# ៤-ការសន្និដ្ឋាន

១-ការបញ្ចូលការទាមទារទទួលស្គាល់សន្តតិជន និងការទាមទារបែងចែកមត៌ក ក្នុងនីតិវិធីតែមួយជាមួយគ្នា ជាការអនុវត្តមិនត្រឹមត្រូវតាមច្បាប់។ តាមច្បាប់ នៅពេលគ្មានវិវាទលើការកំណត់សន្តតិជន ឬទ្រព្យសន្តតិកម្ម ត្រូវដោះស្រាយតាមនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។

២-ការទាមទារបែងចែកមត៌កនៅក្នុងនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ករណីភាគីមានវិវាទពាក់ព័ន្ធនឹងទ្រព្យជាមូលដ្ឋាននៃសន្តតិកម្ម ឬមានវិវាទពាក់ព័ន្ធនឹងសន្តតិជន ជាការអនុវត្តមិនត្រឹមត្រូវ។

៣-ក្នុងករណីពិនិត្យឃើញថា ពាក្យសុំបានធ្វើឡើងមិនត្រឹមត្រូវតាមប្រភេទនៃនីតិវិធី ចៅក្រមត្រូវប្រើសិទ្ធិឱ្យបំភ្លឺ ឱ្យភាគីនោះដកពាក្យសុំរបស់ខ្លួន។ ប៉ុន្តែ ក្នុងករណីភាគីមិនដកពាក្យសុំរបស់ខ្លួនទេ ចៅក្រមត្រូវចេញដីកាសម្រេចលើកចោលពាក្យសុំនោះ តាមបញ្ញត្តិមាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

# ៤-ការសន្និដ្ឋាន (ត)

៤-ក្នុងករណីតុលាការកំពុងចាត់ការសំណុំរឿងបែងចែកមត៌កនៅក្នុងនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ប៉ុន្តែ ភាគីមានវិវាទពាក់ព័ន្ធនឹងការទទួលស្គាល់ជាសន្តតិជន ដូច្នេះ ភាគីត្រូវដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់ជាសន្តតិជននៅក្នុងនីតិវិធីពាក់ព័ន្ធនឹងឋានៈបុគ្គល។ ករណីនេះគប្បីបែងចែកសំណុំរឿងឋានៈបុគ្គលនេះ ទៅចៅក្រមដែលកំពុងចាត់ការសំណុំរឿងបែងចែកមត៌ក។ ចៅក្រមទទួលបន្ទុករឿងក្តី គប្បីបញ្ឈប់ការចាត់ការសំណុំរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងមួយអន្លើសិន រងចាំការសម្រេចសេចក្តីទាក់ទងនឹងការទទួលស្គាល់កូន ឬការកំណត់អំពីទ្រព្យដែលជាកម្មវត្ថុនៃសន្តតិកម្មចប់ជាស្ថាពរ។

# ៤-ការសន្និដ្ឋាន (ត)

**៥**-តាមច្បាប់ជាធរមាន ត្រូវមាននីតិវិធីចំនួន ៣ មុននឹងសម្រេចពីការបែងចែងសន្តតិកម្ម (នីតិវិធីបណ្តឹងធម្មតា នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល និងនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង)។ ច្បាប់ និងការអនុវត្ត មិនស្របគ្នា។ ច្បាប់បង្កើតនីតិវិធីផ្សេងគ្នា ប៉ុន្តែ ភាគីចង់ឱ្យសម្រេចក្នុងនីតិវិធីតែមួយដែលឆាប់រហ័ស។

**៦**-ការសម្រេចអំពីទ្រព្យដែលជាសន្តតិកម្ម ដោយមិនបានគិតពីប្រវត្តិនៃទ្រព្យ ពិសេសករណីដីដែលបានមកពីក្រុមសាមគ្គីបង្កបង្កើនផល ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់បុគ្គលផ្សេងទៀតដែលមានលើទ្រព្យ (ទ្រព្យដែលជាសន្តតិកម្មគឺជាទ្រព្យតែមួយភាគតែប៉ុណ្ណោះរបស់មតកជន)។

**៧**-គួរមានការគណនាទ្រព្យមត៌កឱ្យបានត្រឹមត្រូវ មុនបែងចែក។

**៨**-បណ្តឹងទាមទារមោឃភាពមតកសាសន៍មិនត្រូវធ្វើឡើងតាមនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹងនោះទេ។ គួរលើកកម្ពស់ប្រសិទ្ធភាពនៃមតកសាសន៍ក្នុងទម្រង់លិខិតយថាភូតដោយសារការី។

# ៥-សំណើសុំការសម្រេចពីអង្គសន្និបាត

**សម្រាប់ចំពោះមុខ៖**

**១-ត្រូវដោះស្រាយសំណុំរឿង** ឱ្យបានត្រឹមត្រូវតាមច្បាប់ជាធរមាន៖

- មិនត្រូវបញ្ចូលការទាមទារដែលមានប្រភេទនីតិវិធីខុសគ្នា ទៅក្នុងសំណុំរឿងតែមួយទៀតទេ។ នៅពេលមានវិវាទលើការកំណត់សន្តតិជន ត្រូវប្រើនីតិវិធីបណ្តឹងពាក់ព័ន្ធនឹងឋានៈបុគ្គល។ នៅពេលមានវិវាទលើទ្រព្យសន្តតិកម្ម ត្រូវប្រើនីតិវិធីធម្មតា។
- ការទាមទារដែលមិនមាននៅក្នុងឧបសម្ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង ត្រូវប្រើប្រាស់ក្រមនិតិវិធីរដ្ឋប្បវេណី ឬច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល
- មិនគួរសម្រេចអំពីវិវាទសិទ្ធិកម្មសិទ្ធិលើទ្រព្យសន្តតិកម្ម ដោយដីកាសម្រេចនៅក្នុងនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងទេ។

❖ ចៅក្រមមានសិទ្ធិសម្រេចបែងចែកទ្រព្យដែលជាប់បន្ទុកដើម្បីធានាបំណុល។ ការបែងចែងនេះ មិនប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បំណុលនោះទេ។ ទ្រព្យដែលបានបែងចែកនៅតែជាប់បន្ទុកធានាបំណុលដដែល។

❖ ចៅក្រម ត្រូវប្រើប្រាស់ឆន្ទានុសិទ្ធិ និងសិទ្ធិឱ្យបំភ្លឺឱ្យបានទូលំទូលាយស្របតាមច្បាប់ដើម្បីកំណត់សន្តតិជន កំណត់ទ្រព្យ និងវិធីនៃការបែងចែក ធានាថា ការសម្រេចនេះអាចបញ្ចប់វិវាទបាន។

២-គួរមានទម្រង់គំរូដីកាសម្រេចបែងចែកមត៌កនៅក្នុងរឿងក្តីទាក់ទងនឹងសន្តតិកម្ម។

៣-រឹតបន្តឹងការអនុវត្តឱ្យបានត្រឹមត្រូវនូវមតកសាសន៍ដោយលិខិតយថាភូតដែលធ្វើឡើងដោយសារការី ដើម្បីលើកកម្ពស់វិជ្ជាជីវៈសារការី។

៤-គួរមានកិច្ចប្រជុំពិភាក្សាជាមួយនឹងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ជាដើម ដើម្បីពង្រឹងការអនុវត្តឱ្យបានត្រឹមត្រូវស្របតាមច្បាប់។

**<u>សម្រាប់រយៈពេលវែង៖</u>** គួរធ្វើវិសោធនកម្មច្បាប់នីតិជាធរមាន ដោយពិនិត្យលទ្ធភាពបង្កើតឱ្យមាននីតិវិធីដាច់ដោយឡែកសម្រាប់ដោះស្រាយសំណុំរឿងសន្តតិកម្ម នៅក្នុងនីតិវិធីរួមតែមួយតែម្តង (សន្តតិជន, ការកំណត់ទ្រព្យសន្តតិកម្ម និង ការបែងចែងសន្តតិកម្ម)៕



# សូមអរគុណ !